# ការរីកចម្រើនធូរធារ និងការចុះក្រះ បម្រែបម្រួលជីវភាពជនជាតិព្នងក្នុងឃុំពីរនៅខេត្តមណ្ឌលគិរី[1]

## សេចក្តីផ្តើម

អត្ថបទមួយចុះក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា នៅឆ្នាំ២០០៤ បានគូសបង្ហាញពី ការផ្លាស់ប្តូរក្នុងជីវភាពប្រជាជនដើមជនជាតិព្នងក្នុងឃុំពីរនៅខេត្តមណ្ឌលគិរី ដែលជាលទ្ធផលនៃកំណើនសកម្មភាពទីផ្សារ និងការថយចុះធនធានធម្មជាតិ (McAndrew *et al.* 2004)។ ទោះបីមានការបំផ្លិចបំផ្លាញធនធានព្រៃឈើតាមរយៈ សម្បទានព្រៃឈើ ការកាប់ឈើខុសច្បាប់ និងការបរបាញ់គ្មានច្បាប់អនុញ្ញាតក្តី ក៏អ្នកស្រុកព្នងក្នុងឃុំដាក់ដាំ និងឃុំស្រែព្រះ នៅតែបន្តពឹងផ្អែកច្រើនលើធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត។ កន្លងមកការបន្សាំទៅនឹងការថយចុះធនធានធម្មជាតិ មានជាចម្បង ការទ្រទ្រង់ជីវិតតាមមធ្យោបាយតិចជាងមុន និងការប្រឹងពង្រីកដែនទាញយកផលពីប្រភពធនធានដែលបានថយចុះនេះ។ ដោយសារយុទ្ធសាស្ត្រចិញ្ចឹមជីវិតនៃគ្រួសារ ច្រើនពឹងផ្អែកលើលទ្ធភាពក្នុងតំបន់ និងកង្វះជម្រើសផ្សេងសម្រាប់ដោះស្រាយក្នុងរយៈពេលខ្លីនោះ លទ្ធភាពប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ នៅតែសំខាន់បំផុតសម្រាប់ការទ្រទ្រង់ជីវិតគ្រួសារ។ អត្ថបទនេះ ធ្វើការប្រៀបធៀបលទ្ធផលស្រាវជ្រាវនាពេលថ្មីៗ ទៅនឹងលទ្ធផលសិក្សាពីមុនៗ ដើម្បីពិនិត្យពីបម្រែបម្រួលយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារ ក្នុងឃុំដាក់ដាំ និងឃុំស្រែព្រះ ក្នុងរយៈពេល ៩ឆ្នាំចុងក្រោយ។ ការស្រាវជ្រាវនេះ បានលើកជាសំណួរថា តើការពឹងផ្អែករបស់គ្រួសារទៅលើធនធានធម្មជាតិបានផ្លាស់ប្តូរយ៉ាងណា តើភាពក្រីក្រតាមគ្រួសារបានផ្លាស់ប្តូរយ៉ាងណា និង តើគ្រួសារជាទូទៅបានរីកចម្រើនធូរធារ ឬកាន់តែចុះក្រ។ ការស្រាវជ្រាវនេះ ក៏ព្យាយាមផ្តល់ព័ត៌មានបន្ថែមអំពីប្រជាជនដើមម្ចាស់ស្រុក ជូនដល់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការបង្កើតគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាជាមូលដ្ឋានដើមដែលធ្វើឡើងក្នុងឆ្នាំ២០០២ និង ២០០៣ ដោយអង្គការស៊ីដសេកម្ពុជា (CIDSE Cambodia) (McAndrew *et al.* 2003) និងការស្រាជ្រាវធ្វើឡើងក្នុងឆ្នាំ២០១២ ដោយ មជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍ (ADIC) បានប្រើវិធីសាស្ត្រចម្រុះ រួមមាន៖ អង្កេតគ្រួសារ ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ ការវាយតម្លៃនៅទីជនបទដោយមានការចូលរួម និងការប្រើទិន្នន័យប្រភពទី២។ អង្កេតគ្រួសារក្នុងការសិក្សានីមួយៗ បានធ្វើឡើងនៅគ្រប់ភូមិក្នុងឃុំទាំងពីរ ដោយផ្អែកលើការជ្រើសយកគំរូតាង ២៥% ដោយចៃដន្យ និងបានជ្រើសរើស និងបណ្តុះបណ្តាលជនជាតិព្នងឲ្យធ្វើជាអ្នកសួរសម្ភាសន៍។ អ្នកធ្វើសម្ភាសន៍ សួរសំណួរភាគច្រើនជាភាសាព្នង និងកត់ត្រាចម្លើយជាភាសាខ្មែរ។ តម្លៃជាសាច់ប្រាក់នៃកម្រៃទទួលបានផ្សេងៗនិងផលចំណេញបានពីការផលិតនិងលក់ទំនិញគឺអ្នកឆ្លើយសម្ភាសន៍បានផ្តល់ឲ្យដោយផ្ទាល់។ តម្លៃមធ្យមជាសាច់ប្រាក់សម្រាប់ផលិតផលដទៃទៀត បានកំណត់ឡើងតាមរយៈ ការពិភាក្សាតាមក្រុមស្នូលជាមួយនឹងអ្នកផ្តល់ព័ត៌មានគន្លឹះ ក្នុងភូមិទាំងអស់នៅឃុំទាំងពីរ។ ដោយមានតម្លៃមធ្យមជាសាច់ប្រាក់ទាំងនេះ គេអាចគណនាតម្លៃជាសាច់ប្រាក់នៃផលិតផលឯទៀតៗរបស់គ្រួសារ ដែលអ្នកឆ្លើយសម្ភាសន៍បានប្រាប់ និងប៉ាន់ប្រមាណពីចំណូលគ្រួសារប្រចាំឆ្នាំ។ ការចុះសិក្សាដល់កន្លែងសម្រាប់ការស្រាវជ្រាវនេះ បានធ្វើឡើងនៅឃុំដាក់ដាំ និងឃុំស្រែព្រះ ចាប់ពីខែមករា ដល់ ឧសភា ២០១២។

## ការផ្លាស់ប្តូរជីវភាពនៅឃុំដាក់ដាំ

ការប្រៀបធៀបតម្លៃជាសាច់ប្រាក់នៃចំណូលគ្រួសារ នៅឃុំដាក់ដាំ ពីឆ្នាំ២០០៣ ដល់ ២០១២ បង្ហាញពីការប្រែប្រួលចម្បងៗក្នុងសេដ្ឋកិច្ចនៅមូលដ្ឋាន (តារាង ១) ហើយជាសំខាន់ចំណូលប្រចាំឆ្នាំជាមធ្យមរបស់គ្រួសារសំណាក ដែលបានកើន ៣,៤ដងពី ១.៨៧១.៦៣១រៀល (USD៤៦៨) នៅឆ្នាំ២០០៣ ដល់ ៦.៣១២.៨៣២រៀល (USD១៥៧៨) នៅឆ្នាំ២០១២។ កំណើនសេដ្ឋកិច្ចនៅឃុំដាក់ដាំ បណ្តាលជាចម្បងមកពី ចំណូលបានពីផលិតកម្មដំឡូងឈើសម្រាប់លក់យកប្រាក់ នៅតាមចំការក្នុងតំបន់ខ្ពង់រាប និងចំណូលពីការងារមានប្រាក់កម្រៃ ជាពិសេសការងារធ្វើពលកររកសិកម្ម។ អត្រាអតិផរណាខ្ពស់ក្នុងចន្លោះពេលនោះ ក៏បានរួមចំណែកក្នុងកំណើនដ៏ខ្ពស់នៃចំណូលនេះដែរ។ ចំណូលទទួលបានពីដំណាំតំបន់ខ្ពង់រាប កើនពី ២៤,៨% នៃប្រាក់ចំណូលគ្រួសារសរុបនៅឆ្នាំ២០០៣ ដល់ ៣៨,៤% នៅឆ្នាំ២០១២។ ចំណូលពីផលិតកម្មដំឡូងឈើតែមួយមុខ បានរួមចំណែក ២២,៩% នៃប្រាក់ចំណូលគ្រួសារសរុបនៅឆ្នាំ២០១២។ ស្រដៀងគ្នាដែរ ចំណូលពីការងារមានប្រាក់កម្រៃ កើនពី ៨,៦% នៅឆ្នាំ២០០៣ ដល់ ២០% នៅឆ្នាំ២០១២ រីឯចំណូលពីការបរបាញ់និងដាក់អន្ទាក់សត្វ គិតជាភាគរយនៃចំណូលគ្រួសារសរុប បានធ្លាក់ចុះពី ២៨,២% នៅឆ្នាំ២០០៣ មកត្រឹម ៩,១% នៅឆ្នាំ២០១២។

កំណើនជាភាគរយនៃ តម្លៃជាសាច់ប្រាក់នៃដំណាំតំបន់ខ្ពង់រាប មានលក្ខណៈគួរកត់សម្គាល់ខ្លាំង ព្រោះវាសមាមាត្រគ្នានឹងការធ្លាក់ចុះតម្លៃជាសាច់ប្រាក់នៃស្រូវតំបន់ខ្ពង់រាប។ ពីឆ្នាំ ២០០៣ ដល់ ២០១២ តម្លៃជាសាច់ប្រាក់នៃផលិតកម្មស្រូវតំបន់ខ្ពង់រាបធ្លាក់ចុះពី១០,៣%មកត្រឹម៥,៩%នៃចំណូលគ្រួសារសរុប ដោយសារផលិតភាពទាបនៃការដាំដុះស្រូវតំបន់ខ្ពង់រាប និងការ

[1] រៀបរៀងដោយ សូ ដាន, ហាក់ សុចន្នី, អឿ អ៊ីល និង John McAndrew ជាបុគ្គលិកនៃមជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍ (ADIC)។ អត្ថបទនេះ ផ្អែកលើការសិក្សារបស់ ADIC ស្តីពី "សន្តិសុខស្បៀង និងបម្រែបម្រួលការប្រើប្រាស់ដី នៅឃុំពីរ ក្នុងខេត្តមណ្ឌលគិរី" ដែលនឹងចេញផ្សាយនាពេលខាងមុខ និងទទួលបានជំនួយគាំទ្រពី IDRC តាមរយៈវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល។

តារាង ១៖ តម្លៃគិតជាប្រាក់ជាមធ្យមនៃចំណូលគ្រួសារនៅឃុំដាក់ដាំ ឆ្នាំ២០០៣ និង ២០១២ (ជារៀល)*

| យុទ្ធសាស្ត្រ | 2003 | | 2012 | |
|---|---|---|---|---|
| | រៀល | ភាគរយ | រៀល | ភាគរយ |
| ដំណាំតំបន់ខ្ពង់រាប (សរុប) | 464877 | 24.8 | 2425270 | 38.4 |
| ស្រូវតំបន់ខ្ពង់រាប | (193292) | (10.3) | (371265) | (5.9) |
| ដំណាំតំបន់ខ្ពង់រាប (ក្រៅពីស្រូវ) | (271585) | (14.5) | (2054005) | (32.5) |
| ដំឡូងឈើ | ** | ** | (1444172) | (22.9) |
| គ្រាប់ស្វាយចន្ទី | ** | ** | (3176) | (0.05) |
| ស្រូវដីសើម | 4615 | 0.2 | 53235 | 0.8 |
| ការចិញ្ចឹមជ្រូក | 242308 | 12.9 | 377459 | 6.0 |
| ការចិញ្ចឹមមាន់ | 65077 | 3.5 | 99247 | 1.6 |
| ការចិញ្ចឹមទា | 7692 | 0.4 | 12647 | 0.2 |
| ស្បៀងអាហារប្រមូលបានពីព្រៃ | 46769 | 2.5 | 190691 | 3.0 |
| ផលិតផលឯទៀតប្រមូលបានពីព្រៃ | 252376 | 13.5 | 856175 | 13.6 |
| ជ័រទឹក | (34415) | (1.8) | ( 635) | (0.0) |
| ការបរបាញ់និងដាក់អន្ទាក់សត្វ | 527405 | 28.2 | 576486 | 9.1 |
| ការចាប់ត្រី | 32412 | 1.7 | 69494 | 1.1 |
| ការផលិតនិងលក់ទំនិញ | 40708 | 2.2 | 98082 | 1.6 |
| ការទិញនិងលក់ទំនិញ | 26069 | 1.4 | 141176 | 2.2 |
| ការងារមានប្រាក់កម្រៃ | 161323 | 8.6 | 1265529 | 20.0 |
| ប្រាក់ផ្ញើពីកូនៗនិងសាច់ញាតិមិនរាប់ជាសមាជិកគ្រួសារ | ** | ** | 147341 | 2.3 |
| សរុប | **1871631** | **99.9** | **6312832** | **99.9** |
| | **N=65** | | **N=85** | |

*៤០០០រៀល ស្មើនឹងមួយដុល្លារអាមេរិក

**ទិន្នន័យមិនអាចរកបាន

ថយចុះសមាមាត្រគ្នានៃចំនួនគ្រួសារដាំស្រូវ នៅតំបន់ខ្ពង់រាប។ ម្យ៉ាងទៀត តម្លៃជាសាច់ប្រាក់នៃស្រូវតំបន់ខ្ពង់រាប និងដំណាំតំបន់ខ្ពង់រាប (ក្រៅពីស្រូវ គ្រាប់ស្វាយចន្ទី និងដំឡូងឈើ) វាទាបជាខ្លាំងជាង ដំឡូងឈើតំបន់ខ្ពង់រាប។ នៅឆ្នាំ២០១២ នៅឃុំដាក់ដាំ តម្លៃជាសាច់ប្រាក់ជាមធ្យមនៃស្រូវតំបន់ខ្ពង់រាបសម្រាប់អ្នកដាំដុះស្រូវ ៦៥នាក់ ដែលត្រូវបានអង្កេត គឺ ៤៨៥.៥០០រៀល រីឯតម្លៃជាសាច់ប្រាក់ជាមធ្យមនៃដំណាំតំបន់ខ្ពង់រាប (ក្រៅពីស្រូវ គ្រាប់ស្វាយចន្ទី និងដំឡូងឈើ) របស់អ្នកដាំដុះនៅតំបន់ខ្ពង់រាបក្នុងអង្កេត គឺ ៦៦៩.៦៨១រៀល និងតម្លៃជាសាច់ប្រាក់ជាមធ្យមនៃផលដំឡូងឈើរបស់អ្នកដាំដំឡូងឈើ ៦៨នាក់ ក្នុងអង្កេត គឺ ១.៨០៥.២២១រៀល។ គ្រួសារនានានៅឃុំដាក់ដាំ មានចំណូលចិត្តទទួលយក និងពង្រីកការដាំដុះដំឡូងឈើនៅក្នុងកសិដ្ឋានតំបន់ខ្ពង់រាបរបស់ខ្លួន។ ក្នុងពេលជាមួយគ្នា យុទ្ធសាស្ត្រនេះ ក៏នាំឲ្យគ្រួសារទាំងនោះ ត្រូវងាយរងគ្រោះដោយសារបម្រែបម្រួលតម្រូវការនៃទីផ្សារដំឡូងឈើដែរ។

ចំណែកនៃចំណូលគ្រួសារនៅឃុំដាក់ដាំ គិតតាមប្រភពចំណូល បានបង្ហាញពីការផ្លាស់ប្តូរចម្បងៗដែលកើតមានឡើងក្នុងជីវភាពរស់នៅក្នុងឃុំពីឆ្នាំ២០០៣ ដល់ ២០១២។ ចំណែកនៃចំណូលគ្រួសារបានពីការដាំដំណាំ កើនពី ២៥% នៅឆ្នាំ ២០០៣ ដល់ ៣៩% នៅឆ្នាំ២០១២។ ស្រដៀងគ្នាដែរ ចំណូលពីការងារមានប្រាក់កម្រៃ និងប្រាក់ផ្ញើមកផ្ទះ កើនពីត្រឹម ៨% នៅឆ្នាំ២០០៣ ដល់ ២២% នៅឆ្នាំ២០១២។ ផ្ទុយទៅវិញ ចំណូលពីផលិតផលព្រៃឈើ ការប្រមាញ់ និងដាក់អន្ទាក់ ធ្លាក់ចុះពី ៤៤% នៅឆ្នាំ២០០៣ មកត្រឹម ២៦% នៅឆ្នាំ២០១២ រីឯចំណូលពីការចិញ្ចឹមជ្រូក និងមាន់ទា ធ្លាក់ចុះពី ១៧% នៅឆ្នាំ២០០៣ មកត្រឹម ៨% នៅឆ្នាំ២០១២ (រូបភាព ១)។

សរុបមក ការរីកដុះដាលសេដ្ឋកិច្ចបែបទីផ្សារនៅឃុំដាក់ដាំ បានជំរុញឲ្យមានការផ្លាស់ប្តូរពី កសិកម្មចិញ្ចឹមពោះនៅតំបន់ខ្ពង់រាប ទៅជាផលិតកម្មដំឡូងឈើលក់យកប្រាក់វិញ។ តម្រូវការកម្លាំងពលកម្មសម្រាប់ដាំដំឡូងឈើ ក៏បានបង្កើនឱកាសការងារខាងកសិកម្មដែរ។ លទ្ធភាពធំជាងមុនក្នុងការរកប្រាក់ពីផលិតកម្មដំឡូងឈើ ធ្វើឲ្យគ្រួសារនានាកាត់បន្ថយការចិញ្ចឹមជ្រូក និងមាន់ទា។ វិធានការអភិរក្សរឹងមាំជាងមុនអនុវត្តដោយរដ្ឋបាលព្រៃឈើ និងការថយចុះចំនួនសត្វព្រៃ ដោយសារការបរបាញ់បែបអតិផលកាលពីឆ្នាំមុនៗនោះ ក៏បានកាត់បន្ថយចំណែកនៃចំណូលគ្រួសារបានពីការប្រមាញ់ និងដាក់អន្ទាក់សត្វដែរ។

## ការផ្លាស់ប្តូរជីវភាពនៅឃុំស្រែព្រះ

តម្លៃជាសាច់ប្រាក់នៃចំណូលគ្រួសារ នៅឃុំស្រែព្រះ ពីឆ្នាំ២០០៣ ដល់ ២០១២ ក៏បង្ហាញពីការផ្លាស់ប្តូរយ៉ាងសំខាន់នៃសេដ្ឋកិច្ចក្នុងតំបន់នោះ (តារាង២)។ ចំណូលប្រចាំឆ្នាំជាមធ្យមនៃគ្រួសារជាសំណាក បានកើន ៤,៨ដង ពី ២.១១៤.១២៥រៀល (៥២៩ដុល្លារ) នៅឆ្នាំ២០០៣ ដល់ ១០.១៦៩.២១៨រៀល (២៥៤២ដុល្លារ) នៅឆ្នាំ២០១២។ កំណើនសេដ្ឋកិច្ចនៅឃុំ

រូបភាព ១៖ ចំណែកនៃចំណូលគ្រួសារនៅឃុំដាក់ដាំ គិតតាមតាមប្រភពចំណូល ឆ្នាំ២០០៣ និង ២០១២




ស្រែព្រះ កើតឡើងជាចម្បងពី ចំណូលបានពីផលិតកម្មដំណាំលក់យកប្រាក់ ដូចជា ដំឡូងឈើ និងគ្រាប់ស្វាយចន្ទី នៅតាមកសិដ្ឋានតំបន់ខ្ពង់រាប។ អត្រាអតិផរណាខ្ពស់ក្នុងឆ្នាំទាំងនោះ ក៏បានរួមចំណែកក្នុង កំណើនដ៏ខ្ពស់នៃប្រាក់ចំណូលដែរ។ ចំណូលបានពីដំណាំតំបន់ខ្ពង់រាប គិតជាភាគរយនៃប្រាក់ចំណូលគ្រួសារសរុប បានកើនពី ១១,៨% នៅឆ្នាំ២០០៣ ដល់ ៣៤,៩% នៅឆ្នាំ២០១២។ ដោយឡែក ចំណូលបានពីផលិតកម្មដំឡូងឈើ និងគ្រាប់ស្វាយចន្ទី បានរួមចំណែក ២៦,៨% នៃចំណូលគ្រួសារសរុបនៅឆ្នាំ២០១២។ តម្លៃជាសាច់ប្រាក់នៃដំណាំស្រូវតំបន់ខ្ពង់រាបគិតជាភាគរយនៃចំណូលសរុបជាមធ្យម បានធ្លាក់ចុះពីឆ្នាំ២០០៣ ដល់ ២០១២ ប៉ុន្តែតម្លៃជាសាច់ប្រាក់នៃដំណាំស្រូវធម្មតាគិតជាភាគរយនៃចំណូលសរុបជាមធ្យម បានកើនឡើង។ ប្រការនេះធ្វើឲ្យអ្នកដាំស្រូវមិនសូវរងគ្រោះខ្លាំងទេ ពីការប្រែប្រួលភ្លាមៗក្នុងទីផ្សារដំណាំលក់យកប្រាក់។

នៅឆ្នាំ២០០៣ អាហារ និងផលិតផលដទៃទៀតដែលប្រមូលបានពីព្រៃ វារួមចំណែករហូតដល់ ៤៣,២% នៃចំណូលគ្រួសារសរុប។ ចំណុចនេះ គូសបញ្ជាក់ពីការពឹងផ្អែកនៃគ្រួសារនៅឃុំស្រែព្រះ ទៅលើធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត។ ផ្ទុយទៅវិញ នៅឆ្នាំ២០១២ អាហារនិងផលិតផលដទៃទៀតដែលប្រមូលបានពីព្រៃ រួមចំណែកប្រមាណត្រឹមតែ ២៤% នៃចំណូលគ្រួសារសរុបប៉ុណ្ណោះ។ ការថយចុះការពឹងផ្អែកលើធនធានព្រៃឈើ បណ្តាលជាចម្បងពីការធ្លាក់ចុះយ៉ាងលឿននៃការប្រមូលជ័រទឹកដែលជាប្រភពចំណូលសំខាន់មួយរបស់គ្រួសារ។ ដើមឈើផ្តល់ជ័រក្នុងភូមិមួយចំនួននៃឃុំស្រែព្រះ គេបានយកជ័រច្រើនហួសប្រមាណ ហើយក៏លែងផ្តល់ផលនៅឆ្នាំ២០១២។ នៅឆ្នាំ២០១០ ដើមឈើយកជ័រប្រមាណ ២០០០ដើម នៅក្នុងភូមិមួយ ត្រូវបានក្រុមហ៊ុនចំការកៅស៊ូមួយកាប់យកអស់ក្រោមរូបភាពសម្បទានដីសេដ្ឋកិច្ច។ ជាលទ្ធផល ចំណូលគ្រួសារសរុបបានមកពីការប្រមូលជ័រទឹក បានធ្លាក់ចុះពី ២៨,៤% នៅឆ្នាំ២០០៣ មកត្រឹម ៤,០% នៅឆ្នាំ២០១២។

ចំណែកនៃចំណូលគ្រួសារនៅឃុំស្រែព្រះ គិតតាមប្រភពចំណូល បានគូសបញ្ជាក់ពីការផ្លាស់ប្តូរសំខាន់ៗនៃជីវភាពរស់នៅក្នុងឃុំ ចាប់ពីឆ្នាំ២០០៣ ដល់ ២០១២។ នៅឆ្នាំ២០០៣ គ្រួសារក្នុងឃុំរកចំណូលបានប្រហែលពាក់កណ្តាល អំពីផលិតផលព្រៃឈើ និងការបរបាញ់និងដាក់អន្ទាក់។ នៅឆ្នាំ២០១២ ចំណូលបានពីប្រភពខាងលើនេះ រួមចំណែកមិនបានមួយភាគបីនៃចំណូលសរុបរបស់ពួកគេផង។ ផ្ទុយទៅវិញ នៅឆ្នាំ២០០៣ ពួកគេរកបានមិនដល់មួយភាគបួននៃប្រាក់ចំណូលសរុបទេ ពីការដាំដំណាំ ប៉ុន្តែនៅឆ្នាំ២០១២ ចំណូលបានពីប្រភពនេះ វាមានដល់ជាងពាក់កណ្តាលនៃចំណូលសរុប។ ចំណែកនៃចំណូលបានពីការចិញ្ចឹមជ្រូក និងមាន់ទា បានធ្លាក់ចុះពីឆ្នាំ២០០៣ ដល់២០១២រីឯចំណែកនៃចំណូលបានពីការងារមានប្រាក់កម្រៃ និងប្រាក់ផ្ញើមកផ្ទះ បានកើនឡើងបន្តិចបន្តួច (រូបភាព ២)។ ជារួម ការរីកដុះដាលសេដ្ឋកិច្ចបែបទីផ្សារនៅឃុំស្រែព្រះ បានបង្កការផ្លាស់ប្តូរពីកសិកម្មចិញ្ចឹមពោះនៅតំបន់ខ្ពង់រាប ទៅជាការដាំដុះនៅតំបន់ដីសើម និងផលិតកម្មដំណាំលក់យកប្រាក់បម្រើទីផ្សារ។ ប្រការនេះ ក៏បានរួមចំណែកកាត់បន្ថយ ការពឹងផ្អែកលើធនធានព្រៃឈើ ជាពិសេសជ័រទឹក និង ការចិញ្ចឹមជ្រូកមាន់ទា។ ឱកាសការងារមានប្រាក់កម្រៃបានកើនឡើង ប៉ុន្តែជាទូទៅវាមានលក្ខណៈក្នុងមូលដ្ឋាន តាមរដូវ និងផ្តល់កម្រៃទាប។

## ភាពក្រីក្រ និងវិសមភាពក្នុងឃុំដាក់ដាំ និងឃុំស្រែព្រះ

នៅឃុំស្រែព្រះ កំណើនសេដ្ឋកិច្ចបណ្តាលឲ្យអត្រាគ្រួសារជាសំណាកដែលរស់នៅក្នុងភាពក្រីក្រ ធ្លាក់ចុះពី ៦៣% នៅឆ្នាំ២០០៣ មកត្រឹម ៤៣% នៅឆ្នាំ២០១២។ ផ្ទុយទៅវិញ កំណើនសេដ្ឋកិច្ចនៅឃុំដាក់ដាំ មិនមានឥទ្ធិពលកាត់បន្ថយភាពក្រីក្រដូច្នេះទេ ព្រោះអត្រាគ្រួសារសំណាកដែលរស់នៅក្នុងភាពក្រីក្របានកើនពី ៥៤% នៅឆ្នាំ២០០៣ ដល់ ៦៥% នៅឆ្នាំ២០១២។ នៅឆ្នាំ២០១២ ភាពក្រីក្រក្នុងឃុំទាំងពីរ មានកម្រិតខ្ពស់ខ្លាំងបើធៀបនឹងអត្រាភាពក្រីក្រ ២៤% ដែលគណនាដោយធនាគារពិភពលោក សម្រាប់គ្រួសារនៅជនបទកម្ពុជាក្នុងឆ្នាំ២០១១។ កម្រិតវិសមភាពចំណូលដែលវាស់វែងដោយមេគុណហ្គីនី (Gini) ក៏មានតួលេខខ្ពស់ដែរ ក្នុងឃុំទាំងពីរ។ នៅឆ្នាំ២០១២ មេគុណហ្គីនី សម្រាប់គ្រួសារសំណាកក្នុងឃុំដាក់ដាំ គឺ ០,៤៣ រីឯសម្រាប់គ្រួសារសំណាកក្នុងឃុំស្រែព្រះ គឺ ០,៣៨។ មេគុណទាំងពីរនេះមានកម្រិតខ្ពស់ជាងមេគុណ ០,២៤ ដែលគណនាដោយធនាគារ

តារាង២៖ តម្លៃជាសាច់ប្រាក់ជាមធ្យមនៃចំណូលគ្រួសារនៅឃុំស្រែព្រះ ឆ្នាំ២០០៣ និង ២០១២ (គិតជារៀល)

| យុទ្ធសាស្ត្រ | 2003 | | 2012 | |
|---|---|---|---|---|
| | រៀល | ភាគរយ | រៀល | ភាគរយ |
| ដំណាំតំបន់ខ្ពង់រាប(សរុប) | 248802 | 11.8 | 3550342 | 34.9 |
| ស្រូវតំបន់ខ្ពង់រាប | (87986) | (4.2) | (270632) | (2.7) |
| ដំណាំតំបន់ខ្ពង់រាប(ក្រៅពីស្រូវ) | (160816) | (7.6) | (3279710) | (32.3) |
| ដំឡូងឈើ | ** | ** | (1996226) | (19.6) |
| គ្រាប់ស្វាយចន្ទី | ** | ** | (729764) | (7.2) |
| ស្រូវវស្សា | 259297 | 12.3 | 1665759 | 16.4 |
| ការចិញ្ចឹមជ្រូក | 211149 | 10.0 | 285896 | 2.8 |
| ការចិញ្ចឹមមាន់ | 58784 | 2.8 | 114547 | 1.1 |
| ការចិញ្ចឹមទា | 2567 | 0.1 | 13160 | 0.1 |
| ស្បៀងអាហារប្រមូលបានពីព្រៃ | 42239 | 2.0 | 130980 | 1.3 |
| ផលិតផលដទៃទៀតប្រមូលបានពីព្រៃ | 870799 | 41.2 | 2303842 | 22.7 |
| ជ័រទឹក | (600845) | (28.4) | (411415) | (4.0) |
| ការបរបាញ់ និងដាក់អន្ទាក់ | 133755 | 6.3 | 774730 | 7.6 |
| ការចាប់ត្រី | 51342 | 2.4 | 247325 | 2.4 |
| ការផលិតនិងលក់ទំនិញ | 35270 | 1.7 | 28491 | 0.3 |
| ការទិញនិងលក់ទំនិញ | 67635 | 3.2 | 227146 | 2.2 |
| ការងារមានប្រាក់កម្រៃ | 132486 | 6.3 | 814453 | 8.0 |
| ប្រាក់ផ្ញើពីកូនៗនិងសាច់ញាតិមិនរាប់ជាសមាជិកគ្រួសារ | ** | ** | 12547 | 0.1 |
| សរុប | 2114125 | 100.1 | 10169218 | 99.9 |
| | **N=74** | | **N= 106** | |

*៤០០០រៀលស្មើនឹងមួយដុល្លារអាមេរិកសម្រាប់អំឡុងពេលទាំងពីរ

**ទិន្នន័យមិនអាចរកបាន

ពិភពលោក សម្រាប់តំបន់ជនបទក្នុងប្រទេសកម្ពុជានៅឆ្នាំ២០១១[២]។

ការធ្លាក់ចុះភាពក្រីក្រជារួមក្នុងឃុំស្រែព្រះ បង្ហាញថា ចំនួនគ្រួសារនៅឃុំស្រែព្រះដែលបានរីកចម្រើនធូរធារនៅឆ្នាំ២០១២ ក៏បានកើនឡើងសមាមាត្រគ្នាដែរ បើធៀបនឹងឆ្នាំ២០០៣។ ផ្ទុយទៅវិញ កំណើនភាពក្រីក្រជារួមក្នុងឃុំដាក់ដាំ បង្ហាញថា នៅឆ្នាំ២០១២ ចំនួនគ្រួសារក្នុងឃុំនេះដែលបានចុះក្រជាងមុន បានកើនឡើងសមាមាត្រគ្នា បើធៀបនឹងឆ្នាំ២០០៣។ម្យ៉ាងទៀតវិសមភាពកម្រិតខ្ពស់នៃចំណូលគ្រួសារជារួមនៅឆ្នាំ២០១២ បង្ហាញថា ទាំងសុខុមាលភាព និងភាពខ្វះខាតផ្នែកសេដ្ឋកិច្ច គេឃើញមាននៅលាយឡំគ្នាក្នុងចំណោមគ្រួសារទាំងឡាយនៅឃុំទាំងពីរ។

ស្ត្រីជាប្រជាជនដើមក្នុងឃុំ ក៏បានឆ្លងកាត់ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចខុសៗគ្នាដែរ។ ក្នុងការពិភាក្សាតាមក្រុមស្នូលតូចៗសម្រាប់នារី មានស្ត្រីមួយចំនួនបានប្រាប់ពីការពង្រីកកសិដ្ឋានគ្រួសារបែបតំបន់ខ្ពង់រាប ដើម្បីទាញយកផលប្រយោជន៍ពីផលិតកម្មដំឡូងឈើ។ស្ត្រីមួយចំនួនទៀតបានត្អូញត្អែរថាគាត់លែងអាចពឹងផ្អែកលើធនធានព្រៃឈើដែលបានថយចុះនោះហើយ ដូច្នេះត្រូវតែទៅធ្វើការងារមានប្រាក់កម្រៃជាពលករខាងកសិកម្មដើម្បីអាចរក្សាសន្តិសុខស្បៀងក្នុងគ្រួសារ។

## សេចក្តីសន្និដ្ឋាន

ការសិក្សាជាមូលដ្ឋាននៅឆ្នាំ២០០៣ បានផ្តល់គំនិតថា ថ្វីបើមានការបំផ្លិចបំផ្លាញធនធានព្រៃឈើ ប្រជាជនដើមជាជនជាតិពួងនៅឃុំដាក់ដាំ និងឃុំស្រែព្រះ នៅតែពឹងផ្អែកខ្លាំងលើធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត។ ក្នុងពេល ៩ឆ្នាំកន្លងទៅនេះ ការពឹងផ្អែកលើព្រៃឈើដែលជាធនធានសំខាន់ក្នុងមូលដ្ឋាន បានចាប់ផ្តើមផ្លាស់ប្តូរ ដោយគ្រួសារនានាក្នុងឃុំបែរទៅកាន់តំបន់ខាងក្រៅ និងចាប់ផ្តើមផលិតដំណាំលក់យកប្រាក់បម្រើទីផ្សារ។ ការរីកដុះដាលសេដ្ឋកិច្ចបែបទីផ្សារនៅឃុំទាំងពីរ បានជំរុញកំណើនសេដ្ឋកិច្ច ដោយមានលទ្ធផលចម្រុះលើការកាត់បន្ថយភាពក្រីក្រ និងវិសមភាពប្រាក់ចំណូលខ្ពស់ក្នុងចំណោមគ្រួសារសំណាក ពោលគឺ គ្រួសារខ្លះបានរីកចម្រើនធូរធារ ហើយគ្រួសារខ្លះទៀតកាន់តែក្រីក្រឡើង។

ពីឆ្នាំ២០០៣-២០១២ គ្រួសារនៅឃុំដាក់ដាំ និងឃុំស្រែព្រះមានការផ្លាស់ប្តូរក្នុងផលិតកម្មកសិកម្ម ដោយពួកគេឈានចេញពីការដាំដុះដំណាំមូលដ្ឋានតំបន់ខ្ពង់រាប សម្រាប់ការចិញ្ចឹមពោះជាសំខាន់ ទៅជាផលិតកម្មដំណាំលក់យកប្រាក់សម្រាប់ទីផ្សារ។

[២] តួលេខឆ្នាំ២០០៣ ផ្អែកលើបន្ទាត់ភាពក្រីក្រ ១០៣៦រៀល/នាក់/ថ្ងៃ សម្រាប់តំបន់ជនបទ ដែលកំណត់ដោយក្រសួងផែនការ នៃរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោក នៃអង្គការសហប្រជាជាតិ (២០០៣)។ តួលេខឆ្នាំ២០១១ ផ្អែកលើបន្ទាត់ភាពក្រីក្រ ៤៤២២រៀល/នាក់/ថ្ងៃ ហើយមេគុណហ្គីនី ០,២៤ សម្រាប់តំបន់ជនបទ ដែលគណនាដោយធនាគារពិភពលោក ផ្អែកលើ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០១១។ ធនាគារពិភពលោក ផ្តល់ការគណនាជាដំបូងៗទាំងនេះ ដល់អ្នកនិពន្ធសម្រាប់ប្រើប្រាស់ក្នុងអត្ថបទនេះ នៅថ្ងៃទី ៤ ធ្នូ ២០១២។

រូបភាព ២៖ ចំណែកនៃចំណូលគ្រួសារនៅឃុំស្រែព្រះ គិតតាមប្រភពចំណូល ឆ្នាំ២០០៣ និង ២០១២




ក្នុងប៉ុន្មានឆ្នាំនោះ ចំនួនអ្នកដាំស្រូវតំបន់ខ្ពង់រាប និងតម្លៃផលស្រូវតំបន់ខ្ពង់រាប បានថយចុះនៅឃុំទាំងពីរ។ មួយចំណែកទៀត នៅឆ្នាំ២០១២ ផលគ្រាប់ស្វាយចន្ទី និងជ័រឡុងឈើ នៅឃុំដាក់ដាំ និងឃុំស្រែព្រះ មានតម្លៃខ្ពស់ជាង តម្លៃសរុបនៃផលស្រូវតំបន់ខ្ពង់រាប និងដំណាំតំបន់ខ្ពង់រាបដទៃទៀត។ នៅឃុំស្រែព្រះ កំណើនការដាំដុះស្រូវ ជួយឲ្យអ្នកដាំស្រូវមិនសូវងាយរងគ្រោះដូចមុន ពីការប្រែប្រួលលក្ខខណ្ឌផ្សេងៗនៃទីផ្សារដំណាំលក់យកប្រាក់។

ការដាំដំណាំលក់យកប្រាក់នៅឃុំទាំងពីរ កើតឡើងព្រមគ្នានឹងការផ្លាស់ប្តូរពីកសិកម្មបែបផ្លាស់ទី ទៅជាការដាំដុះក្នុងកសិដ្ឋានអចិន្ត្រៃយ៍។ ការបង្កើតកសិដ្ឋានអចិន្ត្រៃយ៍ ជួយពង្រីកផ្ទៃដីដាំដុះសម្រាប់ដំណាំលក់យកប្រាក់ និងទប់ស្កាត់ការទន្ទ្រានទៅលើដីទំនេរ។ ទោះយ៉ាងនេះក្តី ការរានព្រៃយកដីថ្មីដែលជាលក្ខណៈចម្បងនៃកសិកម្មបែបផ្លាស់ទី នៅតែកើតមានដដែល។ នៅឆ្នាំ២០១២ មានរបាយការណ៍ថា ៦៤% នៃគ្រួសារសំណាកក្នុងឃុំដាក់ដាំ និង ៥៨% នៃគ្រួសារសំណាកក្នុងឃុំស្រែព្រះ បានកាប់រានព្រៃយកដីប្រើប្រាស់ ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ។ ការបើកប្រើដីធ្លីសម្រាប់ការដាំដំណាំលក់យកប្រាក់ បានជួយជំរុញកំណើនសេដ្ឋកិច្ច ប៉ុន្តែវាបង្កើនការគំរាមកំហែងទៅលើតំបន់ព្រៃឈើ។

ស្របពេលដែលចំណែកនៃចំណូលពីការដាំដុះ បានកើនឡើងនៅឃុំទាំងពីរ ចំណែកនៃចំណូលបានពីផលិតផលព្រៃឈើ ការបរបាញ់និងដាក់អន្ទាក់ បែរជាថយចុះ។ ដោយឡែក ចំណូលគ្រួសារបានពីការបរបាញ់និងដាក់អន្ទាក់នៅឃុំដាក់ដាំ និងចំណូលបានពីការយកជ័រទឹកនៅឃុំស្រែព្រះ បានធ្លាក់ចុះជាខ្លាំងពីឆ្នាំ២០០៣ ដល់ ២០១២។ ទោះយ៉ាងណាក្តី នៅឆ្នាំ២០១២ ផលិតផលព្រៃឈើ ការបរបាញ់និងដាក់អន្ទាក់ នៅតែរួមចំណែករហូតដល់ មួយភាគបួននៃចំណូលគ្រួសារនៅឃុំដាក់ដាំ និងជិតដល់មួយភាគបីនៃចំណូលគ្រួសារនៅឃុំស្រែព្រះ។ ទោះជាធនធានព្រៃឈើ លែងរួមចំណែកធំជាងគេនៅក្នុងចំណូលគ្រួសារដូចកាលពីឆ្នាំ២០០៣ ក្តី ក៏គ្រួសារភាគច្រើននៅឃុំដាក់ដាំ និងស្រែព្រះ នៅតែបន្តពឹងផ្អែកលើការប្រមូលស្បៀងអាហារ និងផលិតផលដទៃទៀតពីព្រៃ ក៏ដូចជាការបរបាញ់និងដាក់អន្ទាក់សត្វព្រៃ ដើម្បីបំពេញបន្ថែមលើប្រាក់ចំណូល និងជីវភាពរបស់ខ្លួន។ លទ្ធភាពប្រើប្រាស់និងគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្សធនធានទាំងនោះ នៅតែសំខាន់បំផុត សម្រាប់សន្តិសុខស្បៀងរបស់គ្រួសារក្នុងឃុំទាំងពីរនៅឆ្នាំ២០១២នេះ គឺដូចគ្នានឹងកាលពីឆ្នាំ២០០៣ ដែរ។

ទន្ទឹមនឹងការលើកទឹកចិត្តឲ្យដាំដុះ និងពង្រីកដំណាំលក់យកប្រាក់ដើម្បីជំរុញកំណើនសេដ្ឋកិច្ច អ្នកបង្កើតគោលនយោបាយក៏ត្រូវពង្រឹងការចូលរួមរបស់ក្រុមជនជាតិភាគតិច ក្នុងការគ្រប់គ្រងធនធានធម្មជាតិដែរ។ ប្រការនេះត្រូវមានឆន្ទៈនយោបាយដើម្បីបង្ក្រាបការជួញដូរឈើខុសច្បាប់តាមតំបន់ ពង្រឹងអនុវត្តច្បាប់គ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានយករ៉ែ អនុវត្តការចុះបញ្ជីដីសហគមន៍តាមច្បាប់ភូមិបាលឆ្នាំ២០០១ និងទទួលស្គាល់សិទ្ធិប្រជាជនដើមក្នុងការយល់ព្រមដោយសេរី និងដោយមានព័ត៌មានគ្រប់គ្រាន់លើការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើដីធ្លី ដែនដី និងធនធានរបស់ពួកគេ ដូចមានចែងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិរបស់ប្រជាជនដើម ដែលប្រទេសកម្ពុជា និង ១៤២ ប្រទេសជាសមាជិកផ្សេងទៀត បានអនុម័តទទួលយកនៅថ្ងៃទី១៣ កញ្ញា ២០០៧។

## ឯកសារយោង

McAndrew, J.P., Mam S., Hong K. & Ky B. (2003), *Indigenous Adaptation to a Decline in Natural Resources: The Experience of Two Phnong Communes in Northeast Cambodia* (Phnom Penh: CIDSE Cambodia)

McAndrew, J.P., Mam S., Hong K. & Ky B. (2004), “Phnong Villagers Adapt to Decline in Natural Resources”, *Cambodia Development Review*, Volume 8, Issue 1, pp. 9-12

Ministry of Planning, Royal Government of Cambodia and the United Nations World Food Programme (2003), *Poverty and Vulnerability Analysis Mapping in Cambodia: Mapping Poverty, Malnutrition, Educational Need, and Vulnerability to Natural Disasters in Cambodia*

Oeur I., Hak S., So D. & J. McAndrew (forthcoming), *Food Security and Land Use Change in Two Mondulkiri Communes* (Phnom Penh: Analyzing Development Issues Centre)